

## សង្ខេបគោលនយោបាយ

# ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើខ្សែសង្វាក់តម្លៃត្រីរ៉ស់នៅតំបន់អាងទន្លេមេគង្គក្រោមនៃប្រទេសកម្ពុជា


**ហាប ណារី, ត្រាយ ប៊ុនថន, ឈុន សេរីវណ្ណ, IFReDI, កម្ពុជា**

**Robert S. Pomeroy – សាកលវិទ្យាល័យ Connecticut, សហរដ្ឋអាមេរិក**


លេខរៀងសង្ខេបគោលនយោបាយ៖ វិច្ឆិការ ២០១៥

## សេចក្តីផ្តើម

ផលិតផលនេសាទក្នុងតំបន់មេគង្គមានសារៈសំខាន់ចំពោះសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភសម្រាប់ប្រជាជនប្រហែល៦០លាននាក់នៃអាងទន្លេមេគង្គក្រោម(LMB)។ ការប្រើប្រាស់ត្រីទឹកសាបនៅកម្ពុជា និងវៀតណាមមានរហូតដល់ ៤០ គ.ក្រ ក្នុងមួយឆ្នាំដែលធ្វើឱ្យប្រទេសទាំងពីរស្ថិតក្នុងចំណោមប្រទេសខ្ពស់ទាំងបីនៅលើពិភពលោក។ ត្រីរួមចំណែកប្រហែល៨១% នៃជាតិប្រូតេអ៊ីនទទួលបានរបស់ប្រជាជននៅប្រទេសកម្ពុជានិង៧០%នៅវៀតណាម។ ជលផលទឹកសាបនៃទន្លេមេគង្គផ្តល់ការងារដល់ប្រជាជនកម្ពុជា១.៦ លាននាក់ក្នុងចំណោមប្រជាជន១៤លាននាក់។

ប៉ុន្តែធនធានជលផលជាច្រើនត្រូវបានធ្វើការនេសាទហួសដែនកំណត់ ហើយជាលទ្ធផលការអភិវឌ្ឍវារីវប្បកម្មត្រូវបានលើកទឹកចិត្តដើម្បីផ្តល់ប្រូតេអ៊ីន ប្រាក់ចំណូល ការងារ និងការចំណូលនាំចេញសម្រាប់កម្ពុជា និងវៀតណាម។ ដូច្នេះពួកវាប្រឈមទៅនឹងកត្តាអាកាសធាតុ និងមិនមែនអាកាសធាតុ (ជាពិសេសការអភិវឌ្ឍធនធានទឹកដូចជា ទំនប់វារីអគ្គិសនី និងការសាងសង់ទំនប់ទឹក) ទាក់ទងនឹងកត្តាការផាស់ប្តូរ។ កត្តានេះនឹងមានឥទ្ធិពលជុំវិញខ្សែសង្វាក់តម្លៃត្រី ហើយវានឹងបង្កបញ្ហាប្រឈមយ៉ាងសំខាន់ចំពោះទិន្នផលជលផល និងវារីវប្បកម្ម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងសុខភាពរបស់ប្រជាជនក្រីក្រ ទីផ្សារ និងពាណិជ្ជកម្ម និងបញ្ហាយេនឌ័រនៅក្នុងតំបន់អាងទន្លេមេគង្គក្រោមនៃប្រទេសកម្ពុជា និងប្រទេសវៀតណាម។ ទន្ទឹមនឹងនេះដែរ, ការយល់ដឹងពេញលេញពីផលប៉ះពាល់នៃកត្តានីមួយៗ និងបញ្ចូលរួម គឺទើបតែចាប់ផ្តើម។

ការបន្សាំត្រូវការជាចាំបាច់ជាបន្ទាន់ដើម្បីជំរុញភាពធន់នៃវិស័យជលផលនិងវារីវប្បកម្ម។ វានឹងមានសារៈសំខាន់ក្នុងការកំណត់លំដាប់ជម្រើសបន្សាំដែលមានសក្តានុពលសម្រាប់លក្ខខណ្ឌជីវសាស្ត្រ និងបច្ចេកទេសផ្សេងៗនៃការចាប់ និងការចិញ្ចឹមត្រីក្នុងអាងទន្លេមេគង្គក្រោម (LMB)។

ឯកសារសង្ខេបគោលនយោបាយនេះនឹងបង្ហាញពីលទ្ធផលនៃការសិក្សាដែលបានពិនិត្យមើលភាពងាយរងគ្រោះដូចដែលបានមើលឃើញដោយអ្នកចិញ្ចឹមត្រី និងអ្នកនេសាទត្រីនៅតំបន់អាងទន្លេមេគង្គក្រោមនៃប្រទេសកម្ពុជា និងវៀតណាម ចំពោះផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដោយប្រើគំនិតនៃខ្សែសង្វាក់តម្លៃទីផ្សារត្រីរស់។

## គោលបំណង

ការសិក្សានេះផ្តោតសំខាន់ទៅលើការបន្សាំដោយស្វ័យភាពនៅកម្រិតកសិដ្ឋាន និងទាញការសន្និដ្ឋានសម្រាប់ផែនការបន្សាំដែលបានគ្រោងទុកដើម្បីដោះស្រាយបញ្ហាកម្រិតកសិដ្ឋាន។ ពេលដែលគ្រួសារនីមួយៗបានឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាសនៅតាមមូលដ្ឋាន រដ្ឋាភិបាលអាចដើរតួនាទីក្នុងការបង្កើនសមត្ថភាពសម្របសម្រួលរបស់អ្នកនេសាទ និងអ្នកចិញ្ចឹមត្រី។

### មូលហេតុនៃការថយចុះបរិមាណត្រីរស់

ការសិក្សាបានបង្ហាញថាបរិមាណផលចាប់ត្រីរស់ ក្នុងមួយគ្រួសារក្នុងប្រទេសកម្ពុជាបានថយចុះដោយសារតែមានកត្តាសំខាន់ជាច្រើនដូចជា ការកើនឡើងចំនួនអ្នកនេសាទ ការប្រើឧបករណ៍នេសាទខុសច្បាប់ (**ឧបករណ៍នេសាទអគ្គិសនី អួនក្រឡាល្អិត និងអួនអូសត្រី ជាដើម**)។

ជាទូទៅផលចាប់ត្រីរស់ជាមធ្យមក្នុងមួយគ្រួសារគឺ១.៤០៨ គីឡូក្រាមក្នុងមួយឆ្នាំ។ បញ្ហាប្រឈមសំខាន់ៗដែលអ្នកនេសាទត្រីរស់បានជួបប្រទះរួមមាន: (១)ការបាត់បង់កន្លែងនេសាទត្រី(២)ការថយចុះផលចាប់ត្រីនិងត្រីក្នុងបឹងធម្មជាតិ (៣)ថ្លៃដើមខ្ពស់ ឧ. ថ្លៃប្រេងឥន្ធនៈ ម្ហូបអាហារ ឧបករណ៍នេសាទត្រី និងសម្ភារៈផ្សេងៗ និង (៤) ការខ្វះខាតដើមទុន។

### ព្រឹត្តិការណ៍ប្រែប្រួលអាកាសធាតុកើតឡើងចំពោះអ្នកពាក់ព័ន្ធនឹងខ្សែសង្វាក់តម្លៃត្រីរស់សំខាន់ៗនីមួយៗនៅក្នុងតំបន់សិក្សា

អ្នកនេសាទ អ្ន កលក់ និ ងអ្នកកែច្នៃទាំងអស់ដែលបាន សម្ភាសនៅក្នុងប្រទេសកម្ពុជាបានរាយការណ៍ថាពួកគេ បានដឹងពីព្រឹត្តិការណ៍ប្រែប្រួលអាកាសធាតុដែលបានកើត ឡើងក្នុងតំបន់របស់ពួកគេ។ ព្រឹត្តិការណ៍គួរឱ្យកត់សម្គាល់




ដែលពួកគេគិតថាជាទម្រង់ការប្រែប្រួល អាកាសធាតុនៅក្នុងតំបន់របស់ពួកគេគឺ ការផ្លាស់ប្តូរទម្រង់ ទឹកភ្លៀង ព្យុះធ្ងន់ធ្ងរ ទឹកជំនន់ គ្រោះរាំងស្ងួត ការផ្លាស់ប្តូរ ទម្រង់ខ្យល់ ការប្រែប្រួលសីតុណ្ហភាពទឹក និងការប្រែប្រួល សីតុណ្ហភាពខ្យល់។

### តារាងវាយតម្លៃភាពងាយរងគ្រោះនៃអ្នកពាក់ព័ន្ធនឹងខ្សែសង្វាក់តម្លៃត្រីរ៉ស់

អ្នកនេសាទមានអារម្មណ៍ថាមានភាពងាយរងគ្រោះច្រើន ដោយសារតែខ្យល់ព្យុះដូចជា មានការលំបាកក្នុងការនេសាទត្រី និងការកើនឡើងគ្រោះថ្នាក់ពីការនេសាទត្រី។

ទន្ទឹមនឹងនេះដែរ អ្នកលក់ត្រីរ៉ស់បានកត់សម្គាល់ពីការរាំងស្ងួត និងការប្រែប្រួលទឹកភ្លៀងដែលជាផលប៉ះពាល់យ៉ាងខ្លាំង និងបង្កឱ្យមានភាពងាយរងគ្រោះបំផុតព្រោះតែភាពរាំងស្ងួតបានកាត់បន្ថយការផ្គត់ផ្គង់ត្រីនិងធ្វើឱ្យតម្លៃត្រីឡើងខ្ពស់។

ពេលដែលការកើនឡើងភ្លៀងធ្វើឱ្យអ្នកលក់មានការលំបាកក្នុងការដឹកជញ្ជូននិងលក់ត្រី។ វាមានភាពខុសប្លែកពីករណីក្រុមទាំងពីរខាងលើបន្តិចក្នុងបរិបទនៃការវាយតម្លៃភាពងាយរងគ្រោះ។ អ្នកកែច្នៃបានរកឃើញថាទឹកភ្លៀង និងព្យុះជាផលប៉ះពាល់ខ្លាំងនិងភាពងាយរងគ្រោះខ្ពស់បំផុត។




### ខ្សែសង្វាក់តម្លៃតាមអ្នកពាក់ព័ន្ធនីមួយៗ

អ្នកនេសាទ បានរាយការណ៍ថាផលប៉ះពាល់សំខាន់នៃការប្រែប្រួលអាកាសធាតុលើអាជីវកម្មរបស់ពួកគេគឺការកាត់បន្ថយការចាប់ត្រី / ការប្រមូលផល / ការផ្គត់ផ្គង់។ ផលប៉ះពាល់ជាក់លាក់បន្ថែមទៀតគឺការកើនឡើងការលំបាកក្នុងការនេសាទត្រីដោយសារធាតុអាកាសនិងអាកាសធាតុ។ ការឆ្លើយតបទាំងនោះមានភាពស្របគ្នានៅគ្រប់ខេត្តទាំងអស់ដែលបានសិក្សា។

អ្នកនេសាទរំពឹងថាផលប៉ះពាល់នៃបំរែបំរួលអាកាសធាតុនៅក្នុងរយៈពេលដប់ឆ្នាំខាងមុខនេះគឺ ការថយចុះផលចាប់ត្រី បង្កើនការលំបាកក្នុងការនេសាទត្រី និងការលំបាកក្នុងការរកប្រាក់ចំណូលពីសកម្មភាពនេសាទ។

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើខ្សែសង្វាក់តម្លៃត្រីរ៉ស់ដោយអ្នកពាក់ព័ន្ធនីមួយៗក្នុងទម្រង់ជាច្រើនដូចបង្ហាញក្នុងក្រាបខាងក្រោម:






**យុទ្ធសាស្ត្របន្សាំនៃអ្នកពាក់ព័ន្ធខ្សែសង្វាក់តម្លៃនីមួយៗ**

**អ្នកនេសាទ**: ផ្លាស់ប្តូរឧបករណ៍នេសាទ, ផ្លាស់ប្តូរតំបន់នេសាទ, បង្កើនថ្លៃដើមផលិតកម្ម, ចំណាយពេលច្រើនលើការនេសាទ និងឈប់នេសាទត្រីរស់,

**អ្នកលក់**: ទិញត្រីទៀតជំនួស ផ្លាស់ប្តូរទៅរកតំបន់ថ្មីៗដែលការជួញដូរមានភាពងាយស្រួល និងមានផលចំណេញកាន់តែច្រើន បង្កើនថ្លៃដើមទិញ ហើយចំណាយពេលទិញត្រីកាន់តែច្រើន។

**អ្នកកែច្នៃ**: ទិញត្រីផ្សេងជំនួស ផ្លាស់ប្តូរទៅតំបន់ថ្មីដែលជាកន្លែងកែច្នៃត្រីមានភាពងាយស្រួល និងទទួលបានផលចំណេញ បង្កើនថ្លៃចំណាយ និងចំណាយពេលទិញត្រីកាន់តែច្រើន។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

- ត្រីរស់គឺ ជាប្រភេទត្រីដែលពេញនិយមសម្រាប់ធ្វើជាអាហារនៅក្នុងប្រទេសកម្ពុជា។
- ផលិតកម្មត្រីរស់ហាក់ដូចជាងាយនឹងរងការប៉ះពាល់ពីកត្តាប្រែប្រួលអាកាសធាតុ និងកត្តាមិនទាក់ទងនឹងអាកាសធាតុដូចជាការអភិវឌ្ឍទំនប់វារីអគ្គិសនីជាដើម។
- រដ្ឋាភិបាលចាំបាច់ត្រូវមានភាពសកម្មជាងមុនក្នុងការធ្វើការសកម្មភាពជាមួយអ្នកពាក់ព័ន្ធផ្សេងៗ ក្នុងខ្សែសង្វាក់ផលិតកម្មត្រីរស់ដើម្បីជួយពួកគាត់ក្នុងការស្វែងយល់ និងរៀបចំចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើអាជីវកម្មរបស់ពួកគាត់។
- អ្នកពាក់ព័ន្ធក្នុងខ្សែសង្វាក់ផលិតកម្មត្រូវចាប់ផ្តើមធ្វើការជាមួយគ្នាឬត្រូវបានរៀបចំដើម្បីអាចចែករំលែក ព័ត៌មាននិងបង្កើតយុទ្ធសាស្ត្របន្សាំសមស្របដើម្បីដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាស ធាតុលើអាជីវកម្មរបស់ពួកគាត់។
- រដ្ឋាភិបាលគួរតែពិចារណាលើការហាមឃាត់ការចិញ្ចឹមត្រីរស់ដើម្បីផ្តល់ជម្រើសជីវភាពបន្ថែមទៅឱ្យគ្រួសារដែលជាយុទ្ធសាស្ត្រនៃការបន្សាំ។
- រដ្ឋាភិបាលគួរតែដាក់សម្ពាធ និងហាមឃាត់រាល់ការប្រើឧបករណ៍នេសាទខុសច្បាប់ ការនេសាទហួសកំណត់ ឬសកម្មភាពផ្សេងៗដែលធ្វើឱ្យខូចខាតដល់ធនធានទាំងអស់នោះដើម្បីធ្វើឱ្យប្រាកដថាវាមាននិរន្តរភាពសម្រាប់តម្រូវការប្រើប្រាស់របស់ប្រជាជន។

The Feed the Future Innovation Lab for Collaborative Research on Aquaculture & Fisheries is funded under USAID Leader with Associates Cooperative Agreement No. EPP-A-00-06-00012-00 and by the participating US and Host Country partners. The contents of this document are the responsibility of the authors and do not necessarily reflect the views or endorsement of USAID or the United States Government.